# គុណប្រយោជន៍និងបញ្ហាប្រឈមក្នុងការប្រើវិធីសាស្ត្របង្រៀនបែបចម្រុះ (Blended Learning) ដើម្បីបង្រៀននិងរៀនភាសាអង់គ្លេស

**ឈោម ជុំរ៉ុង** (សីហា ២០២៣)
**មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ**
**លេខទូរស័ព្ទ៖ ០១៧ ៥៥ ៨៨ ៩៨ / ០៦៩ ៥៥ ៨៨ ៩៨**
**អ៊ីម៉េល៖** chhom.chumrong@gmail.com

## មូលន័យសង្ខេប

ឯកសារនេះមានគោលបំណងបង្ហាញដល់អ្នកអប់រំនិងអ្នកពាក់ព័ន្ធក្នុងវិស័យអប់រំ ជាពិសេសគ្រូបង្រៀនភាសាអង់គ្លេសដើម្បីបន្ថែមការយល់ដឹងស៊ីជម្រៅលើវិធីសាស្ត្របង្រៀនបែបចម្រុះដែលជាវិធីសាស្ត្រដ៏ពេញនិយមមួយក្នុងសតវត្សរ៍ទី២១នេះថាអាចយកមកអនុវត្តក្នុងថ្នាក់រៀនរបស់ខ្លួនដែរឬអត់។ ការសិក្សានេះធ្វើឡើងដោយធ្វើសំយោគបណ្ណាល័យសាស្ត្រលើការសិក្សាស្រាវជ្រាវនានា ពាក់ព័ន្ធនឹងវិធីសាស្ត្របង្រៀនបែបចម្រុះក្នុងការបង្រៀននិងរៀនភាសាអង់គ្លេស។ យោងតាមលទ្ធផលយើងអាចមើលឃើញថាទាំងគ្រូបង្រៀននិងសិស្សានុសិស្សភាគច្រើនមានទស្សនៈនិងឥរិយាបថវិជ្ជមានចំពោះការបង្រៀននិងការរៀនភាសាអង់គ្លេសក្នុងថ្នាក់រៀន ដែលប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះដែលផ្តល់នូវគុណសម្បត្តិជាច្រើន ដូចជាអភិវឌ្ឍស្វយ័តភាពរបស់អ្នករៀនសូត្រ ផ្តល់ការគាំទ្រភាសាជាលក្ខណៈបុគ្គល លើកកម្ពស់ការរៀនលក្ខណៈសហប្រតិបត្តិការ បង្កើនអន្តរកម្មនិងការចូលរួមរៀនសូត្ររបស់សិស្ស ផ្តល់ឱកាសអនុវត្តន៍ច្រើននៅក្រៅថ្នាក់រៀន ធ្វើឱ្យជំនាញភាសារបស់សិស្សប្រសើរឡើង មានប្រសិទ្ធភាពលើការចំណាយ និងសន្សំសំចៃពេលវេលា។ វិធីសាស្ត្រនេះក៏មានបញ្ហាប្រឈមមួយចំនួនសម្រាប់គ្រូបង្រៀននិងសិស្សដូចជាការពឹងផ្អែកខ្លាំងលើបច្ចេកវិទ្យា គម្លាតចំណេះដឹងផ្នែកបច្ចេកវិទ្យា បន្ទុកការងាររៀបចំមេរៀនច្រើនសម្រាប់គ្រូបង្រៀន ទំនួលខុសត្រូវច្រើនសម្រាប់ការរៀនដោយស្វយ័តរបស់សិស្ស និងកង្វះខាតគាំទ្រសម្រាប់សិស្សជាដើម។ ដូច្នេះលទ្ធផលនេះអាចបង្ហាញថាអ្នកអប់រំនិងអ្នករៀបចំកម្មវិធីសិក្សា ជាពិសេសគ្រូបង្រៀនគួរអនុវត្តវិធីសាស្ត្របង្រៀនបែបចម្រុះសម្រាប់ការបង្រៀននិងរៀនភាសាអង់គ្លេស ក៏ដូចជាមុខវិជ្ជាដទៃទៀតដោយសារគុណសម្បត្តិដ៏លើសលុបរបស់វិធីសាស្ត្រនេះ។

**ពាក្យគន្លឹះ៖** វិធីសាស្ត្របង្រៀនបែបចម្រុះ ភាសាអង់គ្លេសជាភាសាបរទេស គុណប្រយោជន៍ បញ្ហាប្រឈម

## ១. សេចក្តីផ្តើម

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះមានគំរូគរុកោសល្យផ្សេងៗ ត្រូវបានយកមកប្រើប្រាស់ដើម្បីសម្រួលការរៀនដោយមានជំនួយពីបច្ចេកវិទ្យា ក្នុងចំណោមនោះក៏មានវិធីសាស្ត្របង្រៀនបែបចម្រុះផងដែរ។ វិធីសាស្ត្របង្រៀនបែបចម្រុះដែលគេហៅថា វិធីសាស្ត្រកូនកាត់ផងដែរនោះ គឺជាវិធីសាស្ត្រអប់រំមួយដែលផ្សំការបង្ហាត់ទល់មុខគ្នាតាមបែបប្រពៃណីជាមួយសមាសធាតុរៀនតាមអនឡាញ (Kim & Yoon, 2021)។ អត្ថបទនេះមានគោលបំណងផ្តល់ទិដ្ឋភាពរួមមួយអំពីគុណសម្បត្តិនិងគុណវិបត្តិរបស់វិធីសាស្ត្របង្រៀនបែបចម្រុះ ដោយឆ្លុះបញ្ចាំងនូវគុណប្រយោជន៍ព្រមទាំងបញ្ហាប្រឈមរបស់វិធីសាស្ត្រសម្រាប់ទាំងអ្នកអប់រំនិងសិស្សានុសិស្ស។

គោលការណ៍មូលដ្ឋានដំបូងរបស់វិធីសាស្ត្របង្រៀនបែបចម្រុះ បានចាប់ផ្តើមអនុវត្តក្នុងទសវត្សរ៍ ១៩៦០ នៅក្នុងការអប់រំកម្រិតឧត្តមសិក្សានិងតាមក្រុមហ៊ុនធំៗ ប៉ុន្តែពាក្យបច្ចេកទេសនេះត្រូវបានប្រើជាលើកដំបូងនៅឆ្នាំ ១៩៩៩ នៅពេលមជ្ឈមណ្ឌលរៀនបែបអន្តរកម្មអាម៉េរិកបានចាប់ផ្តើមដំណើរការកម្មវិធីសូហ្វវែរ ដែលបានតាក់តែងសម្រាប់ការបង្រៀនតាមអ៊ីនធើណេត។ មិនដូចជាបច្ចេកវិទ្យាគរុកោសល្យផ្សេងទៀត វិធីសាស្ត្របង្រៀនបែបចម្រុះមិនមានភាពជាអ្នកនិពន្ធច្បាស់លាស់ទេ និងបានវិវត្តក្នុងទម្រង់ជាច្រើនដោយសារមានការព្យាយាមជាច្រើនដងដើម្បីផ្លាស់ប្តូរវិធីសាស្ត្រនិងគោលការណ៍បង្រៀន (Fedorova, 2020)។

យ៉ាងណាមិញ ពាក្យ«វិធីសាស្ត្របង្រៀនបែបចម្រុះ»មានការផ្តល់និយមន័យច្បាស់លាស់និងរាងចង្អៀតដោយលោក ក្លេថុន គ្រីស្តេនសិន (Clayton Christensen) និងសហការីរបស់លោកនៅសាលាធុរកិច្ចហាវ៉ត (Harvard Business School) កាលពីទសវត្សរ៍ឆ្នាំ១៩៩០និងដើមទសវត្សរ៍ឆ្នាំ២០០០។ ក្រុមរបស់លោកបានបង្កើតពាក្យ នវានុវត្តន៍រំខាន (Disruptive Innovation)ដែលបានលុកលុយចូលទិដ្ឋភាពផ្សេងៗរបស់មុខវិជ្ជានៅក្នុងវិស័យជាច្រើន។ នៅក្នុងសៀវភៅមួយមានចំណងជើងថា «ថ្នាក់រំខាន(Disruptive Class)» ដែលលោកបាននិពន្ធនៅឆ្នាំ២០០៨ បានបង្ហាញពីចំណង់របស់លោកដើម្បីបង្កើនសក្តានុពលរបស់មនុស្ស សម្របសម្រួលបែបប្រជាធិបតេយ្យឱ្យមានការចូលរួមខ្លាំងក្លា លើកកម្ពស់ជំនាញ សមត្ថភាព និងឥរិយាបថ ដែលនឹងជួយឱ្យសេដ្ឋកិច្ចរក្សាវិបុលភាពនិងអាចប្រកួតប្រជែងសេដ្ឋកិច្ចបាន ព្រមទាំងបណ្តុះការយល់ដឹងថាមនុស្សអាចមើលឃើញរឿងផ្សេងៗគ្នា ហើយភាពខុសប្លែកគ្នាទាំងនោះគួរទទួលបានការគោរពជាជាងការកាត់សេចក្តី (Kaplan, 2021)។

យោងតាមក្រុមលោក ក្លេថុន គ្រីស្តេនសិន វិធីសាស្ត្របង្រៀនបែបចម្រុះគឺជាវិធីសាស្ត្រអប់រំមួយដែលផ្សំការរៀនសូត្រដឹកនាំដោយគ្រូបង្រៀនជាមួយការរៀនតាមអនឡាញ ដោយមានសមាសធាតុនៃការគ្រប់គ្រងដោយខ្លួនឯងរបស់សិស្សលើវិធី ពេលវេលា ទីកន្លែង និងជំហ៊ានក្នុងការរៀនសូត្រ ព្រមទាំងមានសមាហរណកម្មបទពិសោធន៍រៀនសូត្រតាមអនឡាញនិងបទពិសោធន៍រៀនសូត្រដឹកនាំដោយគ្រូបង្រៀន (Fedorova, 2020)។

ដូច្នេះវិធីសាស្ត្របង្រៀនបែបចម្រុះ មិនមែនជាវិធីសាស្ត្រថ្មីនោះទេនិងផ្ទុយខុសពីអ្វីដែលយើងគិត ដោយសារវិធីសាស្ត្រនេះត្រូវបានប្រើប្រាស់អស់រយៈពេលជាង២០ឆ្នាំមកហើយ។ វិធីសាស្ត្របែបចម្រុះត្រូវបានប្រើប្រាស់ជាលើកដំបូងនៅក្នុងពិភពក្រុមហ៊ុនសាជីវកម្ម ជាយុទ្ធសាស្ត្រមួយដើម្បីអាចឱ្យនិយោជិកបន្តធ្វើការនៅកន្លែងការងារនិងសិក្សានៅពេលដំណាលគ្នា (Sharma, 2010)។

ក្រោយមកវិធីសាស្ត្រនេះបានលេចរូបរាងនៅក្នុងបរិបទអប់រំដោយសារកត្តាបីយ៉ាង៖ (១) លទ្ធភាពចូលប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រនៅក្នុងនិងក្រៅថ្នាក់រៀន, (២) ការពង្រីកសក្តានុពលគរុកោសល្យនៃបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការបង្រៀននិងរៀនសូត្រ (Hong & Samimy, 2010) និង(៣) ភាពស្រងាកចិត្តបង្កដោយការរៀនអនឡាញជាមួយនឹងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញដោយឯករាជ្យ ដែលធ្វើឱ្យមានអារម្មណ៍ឯកោនិងមានកម្លាំងចិត្តទាបនៅក្នុងបរិស្ថានអនឡាញ (McDonald, 2008)។

ការមកដល់នៃការរៀនតាមអនឡាញដែលជាផ្នែកមួយនៃវិធីសាស្ត្របង្រៀនបែបចម្រុះ គឺជាលទ្ធផលនៃបរិវត្តកម្មបែបទំនើបនៃការអប់រំឧត្តមសិក្សា ទន្ទឹមនឹងទិដ្ឋភាពផ្សេងទៀតដូចជាសកលភាវូបនីយកម្ម និងការពង្រីករបស់ឧត្តមសិក្សានៅក្នុងប្រទេសជាច្រើន។ ការកើនឡើងនៃតម្រូវការបង្ហាញថាត្រូវមានការកាត់បន្ថយចំណាយធាតុចូលនិងធនធានពាក់ព័ន្ធនឹងចំនួននិស្សិតបញ្ចប់ការសិក្សាដែលជាធាតុចេញ ហើយដើម្បីដោះស្រាយតម្រូវការនេះ គ្រឹះស្ថានត្រូវប្រើគោលនយោបាយចម្រុះនិងយន្តការផ្តល់ថវិកា ដូចជាការផ្តល់ធាតុចូលបង្រៀននៅក្នុងថ្នាក់តិចនិងប្រើប្រាស់បច្ចេកវិទ្យាដើម្បីភ្ជាប់សកម្មភាពថ្នាក់រៀនជាមួយការរៀនដឹកនាំដោយខ្លួនឯង (Bach et al., 2006)។

ទាក់ទិននឹងនីតិវិធី Badawi (2009) បានកំណត់និយមន័យវិធីសាស្ត្របង្រៀនបែបចម្រុះជាវិធីសាស្ត្រមួយមានភាពបត់បែនដែលបញ្ចូលសកម្មភាពរៀនសូត្រទល់មុខគ្នាផ្ទាល់ជាមួយការអនុវត្តរៀនសូត្រតាមអនឡាញដែលអាចឱ្យសិស្សផ្លាស់ប្តូរមតិនិងការឆ្លើយតបជាលក្ខណៈផ្ទាល់ខ្លួននិងរួមគ្នាលើបួនផ្នែកៈ មតិរបស់អ្នករៀនសូត្រ យុទ្ធសាស្ត្ររបស់អ្នករៀនសូត្រ ឯកសាររៀនសូត្រពិតប្រាកដ និងការវាយតម្លៃដែលមានជម្រើសតាមអនឡាញនិងមិនអនឡាញ។

Lim et al (2007) បានកំណត់និយមន័យវិធីសាស្ត្របង្រៀនបែបចម្រុះចំនួនបីៈ ទីមួយ ជាវិធីសាស្ត្ររៀនសូត្រមួយមានវិធីបង្រៀនច្រើនជាងមួយដែលត្រូវបានប្រើប្រាស់ដើម្បីទទួលបានលទ្ធផលរៀនសូត្រជាអតិបរមានិងដើម្បីកាត់បន្ថយចំណាយពាក់ព័ន្ធនឹងការផ្តល់ជូនកម្មវិធី ទីពីរ ជាការច្របល់វិធីសាស្ត្របណ្តុះបណ្តាលដឹកនាំដោយគ្រូបង្គាត់ជាមួយការរៀនពឹងផ្អែកលើបច្ចេកវិទ្យា និងទីបី ជាការច្របល់ទម្រង់បណ្តុះបណ្តាលក្នុងថ្នាក់រៀនតាមបែបប្រពៃណីនិងសម្បូរដោយអន្តរកម្មជាមួយបច្ចេកវិទ្យានវានុវត្តន៍ណាមួយ។

សម្រាប់លោក Thorn (2003) បានអះអាងថាវិធីសាស្ត្របង្រៀនបែបចម្រុះគឺជាភាពជឿនលឿនដ៏សំខាន់បំផុតមួយក្នុងចំណោមភាពជឿនលឿននានារបស់វិស័យអប់រំក្នុងសតវត្សរ៍ទី២១។ ដូច្នេះបច្ចេកវិទ្យាបង្រៀនបែបចម្រុះអាចត្រូវបានមើលឃើញថាជាបច្ចេកវិទ្យាកម្លាំងរួមមួយដែលអនុញ្ញាតឱ្យយើងប្រើគុណប្រយោជន៍ទាំងការរៀនទល់មុខគ្នានិងតាមអនឡាញប្រកបដោយប្រសិទ្ធភាព និងបំពេញលើគុណវិបត្តិរបស់វិធីមួយក្នុងចំណោមទាំងពីរនេះផងដែរ។

## ២. វិធីសាស្ត្របង្រៀនបែបចម្រុះនៅក្នុងបរិបទភាសាអង់គ្លេសជាភាសាទីពីរ/ភាសាបរទេស

### ២.១ ការអនុវត្តវិធីសាស្ត្របង្រៀនបែបចម្រុះ

ការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះជាគំរូគរុកោសល្យនៅក្នុងថ្នាក់រៀន បានក្លាយជាតម្រូវការដ៏ចាំបាច់មួយក្នុងសម័យកាលសកលភាវូនីយកម្មដែលភាសាអង់គ្លេសមិនត្រឹមតែចាត់ទុកជាភាសាមួយប៉ុណ្ណោះទេ ប៉ុន្តែជាយានមួយដែលអាចមានលទ្ធភាពចូលក្នុងពិភពលោកទាំងមូល។ សព្វថ្ងៃនេះភាសាអង់គ្លេសបានក្លាយជាហេតុផលសម្រាប់លទ្ធផលរកការងារធ្វើនិងត្រូវបានចាត់ទុកជានិមិត្តសញ្ញារបស់ឋានៈក្នុងសង្គមផងដែរ។ វិធីសាស្ត្របង្រៀនបែបចម្រុះជាវិធីសាស្ត្របង្រៀនមួយដែលមានសមត្ថភាពនិងសក្តានុពលដើម្បីអភិវឌ្ឍទំនុកចិត្តនិងគំនិតច្នៃប្រឌិត ព្រមទាំងលើកកម្ពស់ការរៀនដឹកនាំដោយខ្លួនឯង (Self-Directed Learning) ហើយជាវិធីសាស្ត្រសិស្សមជ្ឈមណ្ឌលសុទ្ធសាធដែលអាចឱ្យសិស្សចូលរួមរៀនសូត្រទាំងក្នុងថ្នាក់រៀននិងក្រៅថ្នាក់រៀនដើម្បីអភិវឌ្ឍជំនាញភាសា (Alam et al., 2022)។

នៅក្នុងបរិបទបង្រៀននិងរៀនភាសា Neumeier (2005) បានផ្តល់ក្របខណ្ឌបង្រៀនមួយសម្រាប់ការតាក់តែងបរិស្ថានរៀនសូត្រតាមវិធីសាស្ត្របង្រៀនបែបចម្រុះមានប៉ារ៉ាម៉ែត្រចំនួន ៦ ដែលមានសារៈសំខាន់សម្រាប់គ្រូបង្រៀនភាសាកំណត់ថាតើត្រូវបញ្ចូលវិធីសាស្ត្របង្រៀនបែបចម្រុះទៅក្នុងការអនុវត្តបង្រៀនរបស់ពួកគេដែរឬអត់ៈ ១) វិធី ២) គំរូសមាហរណកម្ម ៣) របាយមាតិការៀននិងកម្មវត្ថុ ៤) វិធីសាស្ត្របង្រៀនភាសា ៥) ការពាក់ព័ន្ធក្នុងការរៀនមុខវិជ្ជា និង ៦) ទីតាំង។

Graham et al. (2003, 2005) បានបង្ហាញហេតុផលចំនួនសម្រាប់ការតាក់តែងឬប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះជាជាងប្រើប្រាស់ជម្រើសបង្រៀនផ្សេងទៀតរួមមាន លើកកម្ពស់គរុកោសល្យបង្រៀននិងរៀន បង្កើនលទ្ធភាពនិងភាពបត់បែន និងបង្កើនប្រសិទ្ធភាពចំណាយ។ លើសពីនេះទៀត វិធីសាស្ត្របង្រៀនបែបចម្រុះមានចែកជាច្រើនកម្រិតដូចជា កម្រិតសកម្មភាព កម្រិតវគ្គសិក្សា កម្រិតកម្មវិធី និងកម្រិតស្ថាប័ន (Graham, 2006)។

ការប្រើវិធីសាស្ត្របង្រៀនបែបចម្រុះកម្រិតសកម្មភាព កើតឡើងនៅពេលសកម្មភាពរៀនសូត្រមានធាតុទាំងទល់មុខគ្នាផ្ទាល់និងទាំងអនឡាញ ដោយអ្នករៀនសូត្រអាចចូលរួមរៀនមេរៀនក្នុងថ្នាក់និងអាចបំពេញមេរៀនដែលនៅសល់តាមអនឡាញឬបញ្ច្រាស់គ្នាមកវិញ។ សម្រាប់កម្រិតមុខវិជ្ជាវិញគឺជាវិធីមួយដែលគេប្រើប្រាស់សាមញ្ញជាងគេក្នុង

វិធីសាស្ត្របង្រៀនបែបចម្រុះ ដោយធ្វើការបញ្ចូលគ្នារវាងសកម្មភាពទល់មុខគ្នាផ្ទាល់និងសកម្មភាពតាមអនឡាញនៅក្នុងវគ្គសិក្សាដែលបានកំណត់។ ចំពោះការប្រើវិធីសាស្ត្របង្រៀនចម្រុះកម្រិតកម្មវិធីសិក្សាច្រើនធ្វើនៅក្នុងវិស័យអប់រំកម្រិតឧត្តមសិក្សាដែលជារឿយៗមាននៅកម្រិតកម្មវិធីបរិញ្ញាបត្រឡើង។ ក្នុងនោះមានគំរូពីរ៖ គំរូទីមួយ អ្នកចូលរួមជ្រើសរើសការប្រេបល់គ្នារវាងវគ្គសិក្សារៀនទល់មុខគ្នាផ្ទាល់និងវគ្គសិក្សារៀនតាមអនឡាញ និងគំរូទីពីរ មានការបញ្ចូលគ្នារវាងវិធីទាំងពីរដែលកំណត់ដោយកម្មវិធីសិក្សា។ សម្រាប់កម្រិតស្ថាប័នវិញសំដៅលើការប្តេជ្ញាចិត្តរបស់ស្ថាប័នចំពោះការបញ្ចូលការបង្ហាត់ទល់មុខគ្នាផ្ទាល់និងការបង្ហាត់តាមអនឡាញ ហើយមានគ្រឹះស្ថានអប់រំឧត្តមសិក្សាជាច្រើនកំពុងបង្កើតគំរូសម្រាប់ការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះនៅកម្រិតស្ថាប័ន (Graham, 2006)។

Graham (2006) ក៏បានបង្ហាញប្រភេទនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះជាបីប្រភេទ។ ប្រភេទទីមួយ គំរូវិធីសាស្ត្របង្រៀនបែបចម្រុះដើម្បីជំរុញ ដែលមានគោលបំណងផ្តល់ភាពបត់បែនបន្ថែមចំពោះអ្នករៀនសូត្រ ឬផ្តល់ឱកាសឬបទពិសោធន៍រៀនសូត្រដូចគ្នាប៉ុន្តែតាមរយៈជំនួយផ្សេងគ្នា។ ប្រភេទទីពីរ វិធីសាស្ត្របង្រៀនបែបចម្រុះដើម្បីលើកកម្ពស់ដែលមានការផ្លាស់ប្តូរគរុកោសល្យបន្តិចបន្តួច មិនមែនជាការផ្លាស់ប្តូរជ្រុលនិយមនូវរបៀបបង្រៀននិងរៀន ដោយអាចមានធនធាននិងឯកសារជំនួយតាមអនឡាញបន្ថែមលើបរិស្ថានរៀនសូត្រទល់មុខគ្នាផ្ទាល់។ ប្រភេទទីបី វិធីសាស្ត្របង្រៀនបែបចម្រុះដើម្បីផ្លាស់ប្តូរដែលមានបំណងឱ្យអ្នករៀនសូត្របង្កើតចំណេះដឹងយ៉ាងសកម្មតាមរយៈអន្តរកម្មប្រកបដោយភាព។

Alam et al. (2022) ក៏បានលើកឡើងពីយុទ្ធសាស្ត្រនិងបច្ចេកទេសដើម្បីប្រើប្រាស់វិធីសាស្ត្របង្រៀនចម្រុះដូចជាការប្រើប្រាស់ទ្រឹស្តីប្លូម ត្រូវការយល់ពីបច្ចេកទេសរៀនបែបសហប្រតិបត្តិការដូចជាការធ្វើការជាក្រុម ការធ្វើការជាគូ និងការគិត ធ្វើជាគូ និងចែករំលែក(Think-Pair-Share) ត្រូវការយល់ពីការប្រើវេទិកាដំណើរការវិធីសាស្ត្របង្រៀនចម្រុះរួមមាន EDMODO, Khan Academy, BYJUS, EDX, COURSERA, NPTEL, GIAN ជាវេទិកាអនឡាញដើម្បីចាត់តាំងការងារនិងទទួលមតិត្រឡប់។ លើសពីនេះទៀតគ្រូបង្រៀនគួរមានការបណ្តុះបណ្តាលពីរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការរៀនសូត្រដូចជា Zoom, Google duo, Google meet, Google classrooms, YouTube, WhatsApp, Telegram, Skype, Facebook និង Messenger ជាដើម។ ការសម្របសម្រួលឯកសាររៀនសូត្រអាចមានប្រសិទ្ធភាពប្រសិនធ្វើដោយម៉ត់ចត់ទៅតាមកម្រិតនិងប្រវត្តិរៀនសូត្ររបស់សិស្ស ហើយគ្រូបង្រៀននិងអ្នកអនុវត្តត្រូវធ្វើឱ្យប្រាកដថាសិស្សរបស់ពួកគេអាចចូលមើលឯកសារបានដោយងាយស្រួល។

## ២.២ ផលប្រយោជន៍របស់វិធីសាស្ត្របង្រៀនបែបចម្រុះ

មានការស្រាវជ្រាវជាច្រើនត្រូវបានធ្វើឡើងទៅលើប្រធានបទវិធីសាស្ត្របង្រៀនបែបចម្រុះនិងការបង្រៀននិងរៀនភាសាអង់គ្លេស ដើម្បីស្វែងរកវិធីប្រើប្រាស់គំរូអប់រំនេះនៅក្នុងការបង្រៀនភាសាអង់គ្លេសជាភាសាទីពីរ/ភាសាបរទេស(ESL/EFL)[1]។ នៅក្នុងការសិក្សារបស់ Marsh (2012) បានលើកឡើងថាការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះអាចផ្តល់ផលប្រយោជន៍ដល់អ្នករៀនភាសាដូចជា អភិវឌ្ឍស្វយ័តភាពរបស់អ្នករៀនសូត្រ ផ្តល់ការគាំទ្រភាសាជាលក្ខណៈបុគ្គល លើកកម្ពស់ការរៀនលក្ខណៈសហប្រតិបត្តិការ បង្កើនអន្តរកម្មនិងការចូលរួមរៀនសូត្ររបស់សិស្ស ផ្តល់ឱកាសដើម្បីអនុវត្តភាសាលើសពីនៅក្នុងថ្នាក់រៀន និងធ្វើឱ្យជំនាញភាសារបស់អ្នករៀនភាសាប្រសើរឡើង។ Owston et al. (2006) បានលើកឡើងនូវសនិទានភាពបីសម្រាប់ការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះ ទីមួយ វិធីសាស្ត្រនេះលើកទឹកចិត្តការអភិវឌ្ឍជំនាញគិតគូនិងបំពេញតម្រូវការរបស់សិស្ស ទីពីរ វិធីសាស្ត្រផ្តល់ភាពបត់បែនច្រើនចំពោះអ្នករៀនសូត្រ ដោយសារការរៀនសូត្រមួយចំនួនកើតឡើងទៅតាមកាលវិភាគពេលរៀនទល់មុខគ្នានិងផ្នែកនៃ

[1] ESL: English as a Second Language, EFL: English as a Foreign Language

ការរៀនសូត្រមួយចំនួនទៀតអាចរៀនតាមអនឡាញទៅតាមពេលវេលាសមស្របសម្រាប់ពួកគេ និងទីបី វិធីសាស្ត្រនេះមានប្រសិទ្ធភាពសមនឹងការចំណាយ។

នៅក្នុងការសិក្សារបស់ Albiladi & Alshareef (2019) បានលើកពីទិដ្ឋភាពរួមចំនួនបីពាក់ព័ន្ធនឹងការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះនៅក្នុងបរិបទភាសាអង់គ្លេសជាភាសាទីពីរ/ភាសាបរទេស។ សម្រាប់ទិដ្ឋភាពទីមួយ វិធីសាស្ត្របង្រៀនបែបចម្រុះជាមធ្យោបាយមួយដើម្បីអភិវឌ្ឍជំនាញភាសារបស់សិស្ស ទិដ្ឋភាពទីពីរ ជាមធ្យោបាយមួយដើម្បីបង្កើនកម្លាំងចិត្តនិងការចូលរួមរៀនសូត្ររបស់សិស្ស និងទិដ្ឋភាពទីបី ជាមធ្យោបាយមួយដើម្បីលើកកម្ពស់បរិស្ថានគួរឱ្យចង់រៀនសូត្រ។

លោក Benhhadj (2021) ដែលបានសិក្សាលើនិស្សិតម៉ារ៉ុកឆ្នាំទីមួយចំនួន ៧៩នាក់ ពាក់ព័ន្ធនឹងផលប៉ះពាល់របស់វិធីសាស្ត្របង្រៀនបែបចម្រុះលើភាពស្ទាត់ជំនាញភាសាអង់គ្លេសជាភាសាបរទេស ដោយចែកជាពីរក្រុម ដែលក្រុមទីមួយទទួលការបង្រៀនតាមវិធីសាស្ត្របង្រៀនចម្រុះ និងក្រុមទីពីរទទួលការបង្រៀនក្នុងបរិស្ថានរៀនសូត្រតាមបែបប្រពៃណី លទ្ធផលបានបង្ហាញថាក្រុមដែលទទួលវិធីសាស្ត្របង្រៀនបែបចម្រុះមានឥទ្ធិពលខ្លាំងជាងលើការលើកកម្ពស់កម្រិតស្ទាត់ជំនាញភាសាអង់គ្លេស។ លទ្ធផលនេះបានបង្ហាញពីប្រសិទ្ធភាពនៃការបញ្ចូលក្នុងដំណើរការរៀន/បង្រៀននៃបច្ចេកវិទ្យាព័ត៌មានជាពិសេសការបង្រៀនតាមបែបចម្រុះ អាចជួយបំពេញតម្រូវការរបស់និស្សិត បង្កើតកម្លាំងចិត្តដល់ពួកគេ និងអាចលើកកម្ពស់ភាពស្ទាត់ជំនាញភាសារបស់ពួកគេបាន។

នៅក្នុងការសិក្សាមួយរបស់ Kim & Yoon (2021)លើនិស្សិតឆ្នាំទីមួយចំនួន ១១៤នាក់ ដែលរៀនវគ្គភាសាអង់គ្លេសនៅសកលវិទ្យាល័យមួយក្នុងប្រទេសកូរ៉េដើម្បីស្វែងយល់ទស្សនៈនិស្សិតភាសាអង់គ្លេសចំពោះការរៀនតាមវិធីសាស្ត្របង្រៀនចម្រុះនិងការរៀនតាមវិធីសាស្ត្របង្រៀនបញ្ច្រាស់ពាក់ព័ន្ធនឹងស្វយ័តភាព ឯករាជ្យភាព និងឥរិយាបថនោះ លទ្ធផលបានបង្ហាញថាក្រុមដែលរៀនសូត្រតាមវិធីសាស្ត្របង្រៀនចម្រុះបានទទួលស្គាល់ពីសារៈសំខាន់របស់ស្វយ័តភាពរបស់អ្នករៀនដើម្បីរៀនសូត្រដោយជោគជ័យ។

Banditvilai (2016) បានធ្វើការសិក្សាមួយលើការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះដើម្បីលើកកម្ពស់ជំនាញភាសានិងស្វយ័តភាពក្នុងការរៀនសូត្ររបស់អ្នករៀនភាសាអង់គ្លេស នៅក្នុងសកលវិទ្យាល័យអាស៊ីមួយជាមួយនិស្សិតជំនាញភាសាអង់គ្លេស ៦០នាក់។ លទ្ធផលបានបង្ហាញថាវិធីសាស្ត្របង្រៀនបែបចម្រុះអាចយកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពដើម្បីបង្កើនការរៀនដោយស្វយ័តនិងបង្កើតកម្លាំងចិត្តរបស់និស្សិត ដោយសារនិស្សិតអាចរៀននិងអនុវត្តភាសារបស់ពួកគេគ្រប់ពេលនិងគ្រប់ទីកន្លែងដែលពួកគេចង់។

Ali et al. (2023) ដែលបានធ្វើការសិក្សាពីផលប៉ះពាល់របស់វិធីសាស្ត្របង្រៀនតាមបែបចម្រុះលើការរៀនវេយ្យាករណ៍របស់និស្សិតអារ៉ាប៊ីសាអ៊ូឌីតឆ្នាំទីមួយដែលរៀនភាសាអង់គ្លេសជាភាសាបរទេសចំនួន ៧៦នាក់ នៅក្នុងការពិសោធរយៈពេល៧សប្តាហ៍ដោយក្រុមមួយរៀនទល់មុខគ្នារយៈពេល៧ម៉ោងនិងអនឡាញ៨ម៉ោង និងក្រុមមួយទៀតរៀនអនឡាញ១៥ម៉ោង លទ្ធផលបានបង្ហាញថាសមត្ថភាពរបស់និស្សិតលើចំណេះដឹងនិងជំនាញវេយ្យាករណ៍ដែលរៀនក្នុងបរិស្ថានរៀនសូត្រតាមវិធីសាស្ត្របង្រៀនបែបចម្រុះ មានភាពខ្ពស់ខ្លាំងជាងការបង្រៀនតាមអនឡាញសុទ្ធ។ ក្រៅពីនេះទៀតវិធីសាស្ត្របង្រៀនបែបចម្រុះ អាចដោះស្រាយបញ្ហាពេលវេលានៅក្នុងថ្នាក់រៀនសម្រាប់សិស្សដើម្បីអនុវត្តនិងបំពេញសកម្មភាពរៀនសូត្របន្ថែម។

លទ្ធផលខាងលើនេះក៏ដូចទៅនឹងលទ្ធផលស្រាវជ្រាវរបស់ Al Bataineh et al. (2019) ដែលបានសិក្សាពីឥទ្ធិពលរបស់វិធីសាស្ត្របង្រៀនបែបចម្រុះលើសមត្ថភាពវេយ្យាករណ៍របស់និស្សិតរៀនភាសាអង់គ្លេសជាភាសាបរទេស ចំនួន ២៨នាក់ បានរកឃើញថានិស្សិតដែលទទួលវិធីសាស្ត្របង្រៀនបែបចម្រុះមានសមត្ថភាពល្អជាងនិស្សិតដែលរៀនតាមបែបប្រពៃណី។ វិធីសាស្ត្រនេះក៏មានឥទ្ធិពលវិជ្ជមានលើសមត្ថភាពវេយ្យាករណ៍ភាសាអង់គ្លេសរបស់និស្សិត

ហើយពួកគេក៏មានសេចក្ដីពេញចិត្តនិងមានកម្លាំងចិត្តខ្លាំងដើម្បីរៀនភាសាអង់គ្លេសដោយប្រើវិធីសាស្ត្របែបនេះ ដែលអាចទាញសេចក្ដីសន្និដ្ឋានបានថាវិធីសាស្ត្របង្រៀនបែបចម្រុះអាចប្រើប្រាស់ជាវិធីសាស្ត្រមួយប្រកបដោយប្រសិទ្ធភាពក្នុងការបង្រៀនវេយ្យាករណ៍ភាសាអង់គ្លេសក្នុងបរិបទភាសាអង់គ្លេសជាភាសាបរទេស។

ទាក់ទិននឹងជំនាញស្ដាប់វិញនៅក្នុងការសិក្សារបស់ Each & Suppasetseree (2021) ដែលបានធ្វើការស្រាវជ្រាវស្ដីពីការរៀនលក្ខណៈសហប្រតិបត្តិការតាមវិធីសាស្ត្រចម្រុះជំនួយដោយទូរស័ព្ទដៃ (Mobile-Blended Cooperative Learning) លើការយល់ក្នុងជំនាញស្ដាប់របស់និស្សិតភាសាអង់គ្លេសចំនួន ១៧៥នាក់ ក្នុងប្រទេសកម្ពុជា។ លទ្ធផលបានបង្ហាញថានិស្សិតបានបង្កើនការយល់ក្នុងការស្ដាប់បន្ទាប់ពីរៀនតាមវិធីសាស្ត្រនេះ ហើយពួកគេមានគំនិតវិជ្ជមាន៖ ទីមួយ គេហទំព័រមានភាពងាយស្រួលប្រើប្រាស់ដោយសារទម្រង់ការប្រើគេហទំព័រក្នុងទូរស័ព្ទដៃមានទំហំធំនិងលទ្ធភាពចូលរៀនសូត្របានគ្រប់ពេលវេលានិងគ្រប់ទីកន្លែង។ ទីពីរ ភាពសប្បាយនិងភាពងាយស្រួលបង្កឡើងដោយល្បែងអប់រំ(Kahoot) ជាមួយលំហាត់អនុវត្តតាមកាលវិភាគដែលបានជួយបង្កើតអារម្មណ៍ថាការរៀនសូត្រអាចកើតឡើងគ្រប់ពេលវេលានិងគ្រប់ទីកន្លែង។ ទីបី និស្សិតបានលើកឡើងថាវិធីសាស្ត្រនេះមានសារៈប្រយោជន៍ដោយសារពួកគេអាចរៀនជំនាញស្ដាប់តាមវិធីសាស្ត្រចម្រុះក្នុងទូរស័ព្ទដៃ ហើយព្រមពេលជាមួយគ្នាពួកគេក៏អាចរៀនជំនាញផ្សេងៗទៀតដូចជាជំនាញស្ដាប់ វេយ្យាករណ៍ ការបញ្ចេញសម្លេង និងវាក្យស័ព្ទជាដើម។ តាមរយៈការរៀនលក្ខណៈសហប្រតិបត្តិការពួកគេមានឱកាសធ្វើការជាគូឬជាក្រុមដែលជាពេលពួកគេអាចបង្ហាញគំនិតផ្ទាល់ខ្លួនរបស់ពួកគេលើលំហាត់ជំនាញស្ដាប់ និងកសាងទំនាក់ទំនងល្អជាមួយមិត្តរួមថ្នាក់របស់ពួកគេផងដែរ។

យោងតាម Fırat Altay & Altay (2019) ដែលបានធ្វើការត្រួតពិនិត្យលើអត្ថបទស្រាវជ្រាវចំនួន១០ ស្ដីពីវិធីសាស្ត្របង្រៀនបែបចម្រុះក្នុងបរិស្ថានរៀនភាសាអង់គ្លេសជាភាសាបរទេស លទ្ធផលបានបង្ហាញថាសិស្សនិងគ្រូបង្រៀនជាទូទៅមានទស្សនៈវិជ្ជមានចំពោះវិធីសាស្ត្របង្រៀនបែបចម្រុះ ហើយផលប្រយោជន៍មានចំនួនលើសលុបលើបញ្ហាប្រឈមដែលពួកគេបានជួបប្រទះនៅក្នុងវិធីសាស្ត្របង្រៀនបែបចម្រុះនេះរហូតដល់៧០% រួមមានការអភិវឌ្ឍភាពស្ទាត់ជំនាញភាសារបស់សិស្ស ការលើកកម្ពស់ការចូលរួមនិងមានអន្តរកម្មច្រើនក្នុងថ្នាក់រៀនភាសា ព្រមទាំងការកើនឡើងនៃកម្លាំងចិត្តរបស់សិស្សជាដើម។

Gulnaz et al. (2020) ដែលបានសិក្សាទាក់ទិននឹងទស្សនៈនិងបទពិសោធន៍របស់គ្រូបង្រៀននិងនិស្សិតភាសាអង់គ្លេសជាភាសាបរទេសលើប្រសិទ្ធភាពរបស់វិធីសាស្ត្របង្រៀនបែបចម្រុះនៅសកលវិទ្យាល័យ Taif នៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត ជាមួយនិស្សិតចំនួន១០០នាក់ លទ្ធផលបានបង្ហាញថាវិធីសាស្ត្របង្រៀនបែបចម្រុះមានកម្រិតភាពខ្លាំងខ្ពស់ជាងបញ្ហាដែនកំណត់របស់វិធីសាស្ត្រ ហើយនិស្សិតយល់ឃើញថាខ្លួនគេផ្ទាល់មានសេចក្ដីពេញចិត្តនៅពេលមានការអនុវត្តភាសាជាគោលដៅតាមរយៈរូបភាពស៊េរើក វីដេអូ សម្លេង អត្ថបទអាន វេទិកាជជែកនិងការពិភាក្សា និងទទួលស្គាល់ថាបរិស្ថានរៀនសូត្រតាមបែបចម្រុះបានលើកកម្ពស់ភាពស្ទាត់ជំនាញផ្នែកភាសារបស់ពួកគេផងដែរ។

ស្រដៀងនឹងការសិក្សាខាងលើ Yoon & Lee (2010) បានសិក្សាពីទស្សនៈរបស់និស្សិតនិងប្រសិទ្ធភាពរបស់វិធីសាស្ត្របង្រៀនបែបចម្រុះនៅក្នុងថ្នាក់ជំនាញសរសេរភាសាអង់គ្លេសជាភាសាទីពីរ ជាមួយនិស្សិតរៀនភាសានៅសកលវិទ្យាល័យចំនួន ៤៧នាក់ ហើយលទ្ធផលបានបង្ហាញថានិស្សិតបានសម្ដែងឥរិយាបថនិងទស្សនៈវិជ្ជមានចំពោះការប្រើវិធីសាស្ត្របង្រៀនបែបចម្រុះនៅក្នុងថ្នាក់រៀនជំនាញសរសេរភាសាទីពីរ ហើយពួកគេជឿជាក់ថាវិធីសាស្ត្រនេះមានប្រយោជន៍ មានការលើកទឹកចិត្ត និងបង្កលក្ខណៈអន្តរកម្ម។ លើសពីនេះទៀតការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះនាំឱ្យមានសមត្ថភាពល្អប្រសើរឡើងលើសមត្ថភាពសរសេររបស់និស្សិត បង្កើនកម្លាំងចិត្តរបស់និស្សិតនិងលើកកម្ពស់ទិដ្ឋភាពផ្សេងៗទៀតយ៉ាងខ្លាំងនៅក្នុងការរៀនភាសាដូចជា អន្តរកម្ម ស្វយ័តភាព និងសហប្រតិបត្តិការ។

លើសពីនេះទៀតផលប្រយោជន៍ដ៏សំខាន់មួយក្នុងចំណោមផលប្រយោជន៍ផ្សេងៗ នៅក្នុងការប្រើវិធីសាស្ត្របង្រៀនបែបចម្រុះនៅក្នុងបរិបទភាសាអង់គ្លេសជាភាសាទីពីរ/ភាសាបរទេស គឺការលើកកម្ពស់បរិស្ថានរៀនសូត្រភាសាដែលដើរតួនាទីមួយយ៉ាងសំខាន់ក្នុងដំណើរការបង្រៀននិងរៀនសូត្រ។ យោងតាមការសិក្សារបស់ Zhang & Zhu (2018) ដែលបានធ្វើការពិនិត្យប្រសិទ្ធភាពរបស់វិធីសាស្ត្របង្រៀនបែបចម្រុះប្រៀបធៀបជាមួយវិធីសាស្ត្របែបប្រពៃណីដើម្បីបង្រៀនភាសាអង់គ្លេសជាភាសាទីពីរជាមួយនិស្សិតចំនួន ៥២៧៦នាក់ ដែលបានចុះឈ្មោះរៀនភាសាបរទេសជាភាសាទីពីរនៅសកលវិទ្យាល័យល្បីមួយក្នុងប្រទេសចិន។ ជាលទ្ធផល និស្សិតដែលរៀនសូត្រដោយប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះមានលទ្ធផលសិក្សាល្អប្រសើរក្នុងវគ្គសិក្សាភាសាបរទេសជាភាសាទីពីរ នៅពេលធៀបជាមួយនិស្សិតផ្សេងទៀតដែលត្រូវបានបង្រៀនដោយវិធីសាស្ត្រទល់មុខគ្នា មានន័យថានិស្សិតដែលស្ថិតក្នុងបរិស្ថានរៀនសូត្រតាមវិធីសាស្ត្របង្រៀនបែបចម្រុះរៀនសូត្រពូកែជាងនិស្សិតដែលស្ថិតនៅក្នុងបរិស្ថានរៀនសូត្រទល់មុខគ្នាផ្ទាល់។ ដូច្នេះលទ្ធផលបានបង្ហាញថាការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះ មានផលប៉ះពាល់ជាវិជ្ជមានលើលទ្ធផលរៀនសូត្ររបស់និស្សិត។

នៅក្នុងការធ្វើសំយោគបណ្ណាល័យសាស្ត្រអំពីប្រសិទ្ធភាពនៃការរៀនអនឡាញ និងការរៀនតាមវិធីសាស្ត្របង្រៀនបែបចម្រុះនៅសាលារៀនរបស់ Topping et a. (2022) ដែលបានធ្វើការត្រួតពិនិត្យឯកសារស្រាវជ្រាវចំនួន ១៣៥៥ឯកសារយកចេញពីមូលដ្ឋានទិន្នន័យដូចជា ERIC, JSTOR, Scopus, Web of Knowledge, Google Scholar, EEF Rapid Evidence Assessment Reviews, EEF Rapid Assessment Single Studies និងឯកសារស្រាវជ្រាវស្ដីពីការរៀនសូត្រពីចម្ងាយការសិក្សា (Studies of Distance Learning) លទ្ធផលបានរកឃើញថាការរៀនតាមការបង្រៀនវិធីសាស្ត្រចម្រុះមានប្រសិទ្ធភាពជាងការបង្ហាត់ធម្មតារហូតដល់ ៨៥% ក្នុងចំណោមឯកសារស្រាវជ្រាវជាមួយនឹងកម្រិតដូចគ្នា ៨% និងអន់ជាង ៣%។ ជាងនេះទៀតវិធីសាស្ត្របង្រៀនចម្រុះល្អប្រសើរខ្លាំងជាងការរៀនតាមអនឡាញ ហើយអន្តរាគមន៍ជាភាសាអង់គ្លេសមានប្រសិទ្ធជាងគេបំផុតក្នុងចំណោមមុខវិជ្ជាផ្សេងៗ។ ក្នុងនោះដែរសិស្សស្រីមានការរៀនសូត្រល្អប្រសើរជាងសិស្សប្រុសផងដែរ។ ដូច្នេះគុណប្រយោជន៍ចម្បងអាចជាលទ្ធភាពសម្រាប់ភាពបត់បែនធ្វើកិច្ចការនិងស្វយ័តភាពរបស់សិស្សដែលលើកទឹកចិត្តយ៉ាងខ្លាំងលើការដាក់កំណត់ដោយខ្លួនឯង។

ពាក់ព័ន្ធនឹងចីរភាពវិញ ការអនុវត្តវិធីសាស្ត្របង្រៀនបែបចម្រុះមានសក្ដានុពលខ្លាំងដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចនិងសង្គមរបស់ចីរភាពបាន។ សម្រាប់ដែនសេដ្ឋកិច្ចរបស់ចីរភាព វិធីសាស្ត្របង្រៀនបែបចម្រុះអាចពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១ «បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់និងគ្រប់ទីកន្លែង» ដោយសារតែចរិកលក្ខណៈរបស់វិធីសាស្ត្របង្រៀនបែបចម្រុះ រួមមានប្រសិទ្ធភាពចំណាយនិងសន្សំសំចៃពេលវេលាអាចជំរុញអ្នករៀនសូត្រទទួលបានការអប់រំ។ ពាក់ព័ន្ធនឹងដែនសង្គមរបស់ចីរភាព ការចូលរួមចំណែកនៃការអនុវត្តវិធីសាស្ត្របង្រៀនបែបចម្រុះគឺជាប់ពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ «ធានាការអប់រំប្រកបដោយគុណភាពនិងបរិយាបន្នសម្រាប់ជនគ្រប់រូបដើម្បីលើកកម្ពស់ការរៀនសូត្រពេញមួយជីវិត» ដោយសារវិធីសាស្ត្របង្រៀនបែបចម្រុះមានប្រើប្រាស់បច្ចេកវិទ្យាជាច្រើនប្រភេទដើម្បីជួយធ្វើឱ្យការអប់រំប្រកបដោយបរិយាបន្ន (Ramalingam et al, 2022)។

ជារួមនៅក្នុងបរិបទភាសាអង់គ្លេសជាភាសាទីពីរ/ភាសាបរទេស វិធីសាស្ត្របង្រៀនបែបចម្រុះអាចយកមកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពដើម្បីអភិវឌ្ឍភាពស្ទាត់ជំនាញផ្នែកភាសារបស់អ្នករៀនភាសាអង់គ្លេស យោងតាមការស្រាវជ្រាវខាងលើ គ្រូបង្រៀនភាសាអាចប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះដើម្បីអភិវឌ្ឍជំនាញផ្សេងៗដូចជាការអាន ការសរសេរ ការនិយាយ និងចំណេះដឹងវេយ្យាករណ៍ជាដើម។ លើសពីនេះទៀតលទ្ធផលនៃការស្រាវជ្រាវទាំងនោះក៏បង្ហាញដែរថាវិធីសាស្ត្រនេះអាចលើកកម្ពស់ដំណើរការរៀនសូត្រនិងលទ្ធផលរបស់អ្នករៀនភាសាអង់គ្លេស ដោយសារ

ពួកគេបានសម្តែងទស្សនៈនិងឥរិយាបថវិជ្ជមានចំពោះការប្រើវិធីសាស្ត្របង្រៀនបែបចម្រុះជាវិធីសាស្ត្របង្រៀនភាសាអង់គ្លេសនោះ។

## ២.៣ បញ្ហាប្រឈមរបស់វិធីសាស្ត្របង្រៀនចម្រុះ

វិធីសាស្ត្របង្រៀនចម្រុះអាចជាបញ្ហាប្រឈមផងដែរសម្រាប់គ្រូបង្រៀន ដូចជាការសិក្សារបស់ Yang (2014) បានបង្ហាញពីបញ្ហាប្រឈមដែលគ្រូបង្រៀនជួបប្រទះរួមមានតួនាទីមានការផ្លាស់ប្តូររបស់គ្រូបង្រៀននិងសិស្ស ការមិនសូវយល់ដឹងពីការកសាងសហគមន៍ កង្វះខាតក្នុងការបណ្តុះបណ្តាលក្នុងវគ្គសិក្សាវិធីសាស្ត្របង្រៀនបែបចម្រុះ និងភាពមិនសូវស្គាល់ប្រព័ន្ធថ្មីឬបច្ចេកវិទ្យានោះ ហើយក្នុងចំណោមបញ្ហាប្រឈមទាំងនេះ ការផ្លាស់ប្តូរតួនាទីរបស់គ្រូបង្រៀនជាបញ្ហាចម្បងជាងគេ។

ស្រដៀងនឹងលទ្ធផលសិក្សាខាងលើ Banados (2006) បានគូសបញ្ជាក់ថាតួនាទីរបស់គ្រូនិងសិស្សបានផ្លាស់ប្តូរយ៉ាងខ្លាំងដោយសារការចូលរួមនៅក្នុងកម្មវិធីវិធីសាស្ត្របង្រៀនបែបចម្រុះ។ សិស្សត្រូវរៀនមានទំនួលខុសត្រូវលើដំណើរការរៀនសូត្ររបស់ពួកគេផ្ទាល់ ហើយគ្រូបង្រៀនត្រូវដើរតួនាទីជាអ្នករៀបចំសម្ភារៈឧទ្ទេស ផលិតករធនធានប្រព័ន្ធផ្សព្វផ្សាយ និងគ្រូបង្ហាត់តាមអនឡាញ។ ដោយសារមានភាពស្មុកស្មាញទាំងនេះ សិស្សក៏ដូចជាគ្រូបង្រៀនអាចពេញចិត្តវិធីសាស្ត្របង្រៀនមួយដោយសារភាពលំបាករបស់វិធីសាស្ត្រមួយផ្សេងទៀត ឬក៏អាចជំទាស់ឬប្រឆាំងនឹងបទពិសោធន៍ទាំងមូលនៃវិធីសាស្ត្របង្រៀនបែបចម្រុះនេះ (Sharma, 2010)។

សម្រាប់បរិបទរៀនភាសាតាមអនឡាញ បានបង្កើតតម្រូវការវិធីសាស្ត្របង្រៀននិងជំនាញបង្រៀនថ្មីដែលខុសប្លែកពីវិធីសាស្ត្រនិងជំនាញដែលធ្លាប់បានប្រើប្រាស់នៅក្នុងវគ្គសិក្សាភាសារៀនទល់មុខគ្នាផ្ទាល់។ គ្រូបង្រៀនមិនត្រឹមតែត្រូវការជំនាញខុសប្លែកពីជំនាញ ដែលពួកគាត់ធ្លាប់ជួបប្រទះនៅក្នុងថ្នាក់រៀនភាសាទល់មុខតាមបែបប្រពៃណីប៉ុណ្ណោះទេ ថែមទាំងត្រូវការជំនាញខុសប្លែកផ្សេងៗពីគ្រូបង្រៀនមុខវិជ្ជាផ្សេងទៀតតាមអនឡាញផងដែរ។ គ្រូបង្រៀនត្រូវធ្វើការផ្លាស់ប្តូរថ្មីលើទស្សនៈនៃពេលវេលានិងទីកន្លែងបង្រៀន បច្ចេកទេសគ្រប់គ្រងតាមអនឡាញ និងវិធីឱ្យសិស្សចូលរួមតាមរយៈទំនាក់ទំនងតាមអនឡាញ (Compton, 2009; Hampel & Stickler, 2005)។

Bonk and Graham (2012) បានបង្ហាញពីបញ្ហាចម្បងចំនួន៦ នៅពេលរៀបចំបរិស្ថានសម្រាប់វិធីសាស្ត្របង្រៀនបែបចម្រុះដូចជា (១)តួនាទីរបស់អន្តរកម្មផ្សាយផ្ទាល់ ដែលពាក់ព័ន្ធនឹងចំនួនអន្តរកម្មនៅក្នុងវិធីរៀនតាមអនឡាញនិងរៀនទល់មុខផ្ទាល់ (២) តួនាទីរបស់ជម្រើសនិងការគ្រប់គ្រងដោយខ្លួនឯងរបស់អ្នករៀន ដែលត្រូវយល់ពីជម្រើសរបស់សិស្សពាក់ព័ន្ធនឹងប្រភេទវិធីសាស្ត្របង្រៀនបែបចម្រុះមួយណា ដែលពួកគេចូលរួមហើយគ្រូអាចណែនាំដោយរបៀបណាហើយវិធីសាស្ត្រនេះប៉ះពាល់យ៉ាងណាទៅលើការរៀនសូត្រ (៣) គំរូសម្រាប់ការគាំទ្រនិងការបណ្តុះបណ្តាល ដែលត្រូវការទាំងទិដ្ឋភាពបច្ចេកវិទ្យាទាំងការបង្រៀនប្រកបដោយគុណភាពសល្យ (៤) ការដោះស្រាយជាមួយគម្លាតឌីជីថល ដែលជាគម្លាតរវាងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងដែលអាចរកបានសម្រាប់បុគ្គលនិងសង្គមនៅកម្រិតសង្គមសេដ្ឋកិច្ចផ្សេងៗគ្នា (៥) ការសម្របតាមវប្បធម៌ ដែលពាក់ព័ន្ធនឹងសម្ភារៈប្រើប្រាស់នៅក្នុងវិធីទាំងពីរជាមួយវប្បធម៌របស់សិស្ស និង(៦)ការស្វែងរកតុល្យភាពរវាងនវានុវត្តន៍និងផលិតកម្ម ដែលភាពតានតឹងអាចកើតមានឡើងនៅចន្លោះក្នុងការការព្យាយាមប្រើនវានុវត្តន៍បច្ចេកវិទ្យាថ្មីនិងសមត្ថភាពផលិតបាននូវលទ្ធផលដែលសមនឹងការចំណាយ។

តាមការសិក្សារបស់ Riel et al (2016) ក៏បានបង្ហាញបញ្ហាប្រឈមចំនួន ៦ ផងដែរដែលគ្រូបង្រៀនជួបប្រទះអំឡុងពេលដំណើរអនុវត្តកម្មវិធីសិក្សាតាមវិធីសាស្ត្របង្រៀនបែបចម្រុះ។ ទីមួយ គ្រូបង្រៀនអាចជួបប្រទះបញ្ហានៅពេលធ្វើសកម្មភាពកម្មវិធីសិក្សាជាមួយសិស្ស ដែលសិស្សអាចមានភាពលំបាកទំនាក់ទំនងជាមួយមិត្តរួមថ្នាក់ដើម្បី

បញ្ចប់កិច្ចការដែលគ្រូចាត់តាំង។ ទីពីរ អាចមានបញ្ហាប្រឈមជាមួយការគ្រប់គ្រងដោយខ្លួនឯងរបស់សិស្ស ដោយសារគ្រូបង្រៀនអាចលំបាករក្សាឱ្យសិស្សផ្តោតលើកិច្ចការរបស់ពួកគេ ដូច្នេះគ្រូត្រូវរក្សាសកម្មភាពឱ្យពាក់ព័ន្ធនិងសកម្ម។ ទីបី ការបង្កើតសេចក្តីរំពឹងទុកដូចជាគោលដៅនិងវត្ថុបំណងដែលអាចសម្រេចបានពាក់ព័ន្ធនឹងការរៀនសូត្ររបស់សិស្សគឺជាបញ្ហាប្រឈមមួយទៀតសម្រាប់គ្រូ។ ទីបួន ការរៀបចំកម្មវិធីសិក្សាពាក់ព័ន្ធការរៀបចំកិច្ចការនិងការស្វែងរកពេលវេលាដើម្បីបង្រៀនមេរៀនព្រមទាំងគ្រោងពេលវេលាដើម្បីបញ្ចប់កិច្ចការ។ ទីប្រាំ នៅពេលអនុវត្តវិធីសាស្ត្រនេះក៏មានបញ្ហាប្រឈមនៅខាងក្រៅថ្នាក់រៀនផងដែរ ដូចជាការរៀបចំកាលវិភាគពេលវេលាចូលរួមសកម្មភាពខាងក្រៅថ្នាក់រៀន។ ទីប្រាំមួយ គ្រូអាចជួបបញ្ហាប្រឈមផ្នែកបច្ចេកវិទ្យា ដែលកើតឡើងអំឡុងពេលដំណើរការអនុវត្តវិធីសាស្ត្របង្រៀនបែបចម្រុះ។

Bijeikienė et al (2011) ដែលបានធ្វើការសិក្សាលើគ្រូបង្រៀនភាសាអង់គ្លេសចំនួន ២៤នាក់ ទាក់ទិននឹងបទពិសោធន៍នៅក្នុងថ្នាក់ភាសាដែលមានជំនួយពីកុំព្យូទ័រ ការអនុវត្តនិងឥរិយាបថរបស់គ្រូបង្រៀនភាសាចំពោះវគ្គសិក្សាដោយប្រើវិធីសាស្ត្របង្រៀនចម្រុះដែលបានបង្កើតឡើងនៅមជ្ឈមណ្ឌលភាសាបរទេសនៃសកលវិទ្យាល័យ Vytautas Magnus លទ្ធផលបានបង្ហាញមតិវិជ្ជមានដូចជាភាពងាយស្រួលក្នុងការចូលរៀន វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល និងការអនុវត្តដែលមានលក្ខណៈទំនាក់ទំនង និងមានការរិះគន់ផងដែរ ហើយកត្តាជាចំណុចអវិជ្ជមានជាងគេនោះគឺកង្វះខាតនៃការប្រាស្រ័យទាក់ទងទល់មុខគ្នាផ្ទាល់ ដោយសារមានសិស្សខ្លះត្រូវការជំនួយនិងការណែនាំបន្ថែមលើកិច្ចការរបស់ពួកគេ។ គ្រូបង្រៀនមួយចំនួនក៏បានមើលឃើញថាសិស្សមួយចំនួនខ្វះកម្លាំងចិត្តចូលរួមក្នុងវេទិកានិងការជជែកតាមអនឡាញផងដែរ។

Alam et al. (2022) ដែលធ្វើការសិក្សាពីប្រសិទ្ធភាពរបស់វិធីសាស្ត្របង្រៀនបែបចម្រុះឬវិធីសាស្ត្រកូនកាត់តាមរយៈការសម្ភាសគ្រូបង្រៀនភាសាអង់គ្លេសចំនួន ២៨នាក់ ដែលបង្រៀនមេរៀនតាមអនឡាញឬវិធីសាស្ត្របង្រៀនចម្រុះ បានលើកបញ្ហាមួយចំនួនរបស់គំរូវិធីសាស្ត្របង្រៀនបែបចម្រុះ ទីមួយតម្រូវការហេដ្ឋារចនាសម្ព័ន្ធក្នុងការចូលរកមាតិកាតាមអនឡាញជាមួយបរិក្ខាអ៊ីនធើណេតល្បឿនលឿនដែលគួរអាចរកបានសម្រាប់សិស្សនិងគ្រូបង្រៀនទាំងអស់ ហើយអ្នករៀបចំគោលនយោបាយគួរមានទំនួលខុសត្រូវដើម្បីផ្តល់ហេដ្ឋារចនាសម្ព័ន្ធល្អដូចជាបន្ទប់អនុវត្តភាសា កម្មវិធីសុហ្វវែរដែលធ្វើបច្ចុប្បន្នភាព អ្នកបច្ចេកទេសគ្រប់គ្រងបន្ទប់អនុវត្តនិងថ្នាក់បង្ហាត់ជាដើម។ បញ្ហាមួយទៀតគឺការសម្របសម្រួលមាតិកានៅក្នុងការប្រើវិធីសាស្ត្របង្រៀនចម្រុះដែលគ្រូបង្រៀនត្រូវធ្វើ ហើយបញ្ហាគឺថាឯកសារបង្រៀនប្រភេទណាដែលសិស្សគួរអនុញ្ញាតឱ្យចូលមើលហើយគ្រូបង្រៀនគួរណែនាំពួកគេច្រើនប៉ុនណា។ បញ្ហាម្យ៉ាងទៀតគឺការវាយតម្លៃនិស្សិតដែលអាចជាបញ្ហាប្រឈមនៅក្នុងការប្រើប្រាស់វិធីសាស្ត្រនេះ។

ជារួមគ្រូបង្រៀនមានបញ្ហាលំបាកក្នុងការយល់ពីការតាក់តែងវគ្គសិក្សាតាមវិធីសាស្ត្របង្រៀនបែបចម្រុះ ហើយពួកគាត់គិតថាការរៀនក្នុងថ្នាក់ជួបមុខគ្នាផ្ទាល់ដូចនៅក្នុងវគ្គសិក្សាភាសាតាមបែបប្រពៃណីគឺមានសារៈសំខាន់ជាង។ ដើម្បីយល់ពីវិធីសាស្ត្របង្រៀនបែបចម្រុះឱ្យបានល្អប្រសើរ គ្រូបង្រៀនគួរទទួលការបណ្តុះបណ្តាល និងជួបពិភាក្សាគ្នាជាទៀងទាត់ដើម្បីចែករំលែកការឆ្លុះបញ្ចាំងរបស់ពួកគេនិងអាចបង្កើតជាសហគមន៍រៀនសូត្រមួយផងដែរ។ លើសពីនេះទៀតការបណ្តុះបណ្តាលគួរធ្វើជាទម្រង់បែបចម្រុះផងនិងការជួបមុខផ្ទាល់ផង ដើម្បីឱ្យគ្រូបង្រៀនប្រើប្រាស់បទពិសោធន៍របស់ពួកគេនិងលើកកម្ពស់ការយល់ដឹងពីវគ្គរៀនសូត្រតាមវិធីសាស្ត្របង្រៀនបែបចម្រុះ (Nissen & Tea, 2012)។

## ៣. សេចក្ដីសន្និដ្ឋាន

យោងតាមការធ្វើសំយោគបណ្ណាល័យសាស្ត្រក្នុងចំណោមការសិក្សាស្រាវជ្រាវទាំងឡាយនៅក្នុងប្រទេសនានារួមទាំងប្រទេសកម្ពុជាខាងលើ យើងអាចមើលឃើញថាទាំងគ្រូបង្រៀននិងសិស្សានុសិស្សភាគច្រើនមានទស្សនៈនិងឥរិយាបថវិជ្ជមានចំពោះការបង្រៀននិងការរៀនភាសាអង់គ្លេសក្នុងថ្នាក់រៀន ដែលប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះដោយសារវិធីសាស្ត្រនេះបានផ្ដល់នូវគុណសម្បត្តិជាច្រើនដូចជាអភិវឌ្ឍស្វយ័តភាពរបស់អ្នករៀនសូត្រ ផ្ដល់ការគាំទ្រភាសាជាលក្ខណៈបុគ្គល លើកកម្ពស់ការរៀនលក្ខណៈសហប្រតិបត្តិការ បង្កើនអន្តរកម្មនិងការចូលរួមរៀនសូត្ររបស់សិស្ស ផ្ដល់ឱកាសអនុវត្តន៍ច្រើននៅក្រៅថ្នាក់រៀន និងធ្វើឱ្យជំនាញភាសារបស់សិស្សប្រសើរឡើង មានប្រសិទ្ធភាពចំណាយ និងសន្សំសំចៃពេលវេលា។ ទោះបីយ៉ាងណាក៏វិធីសាស្ត្រនេះក៏មានបញ្ហាប្រឈមមួយចំនួនសម្រាប់គ្រូបង្រៀននិងសិស្ស ដូចជាការពឹងផ្អែកខ្លាំងលើបច្ចេកវិទ្យា គម្លាតចំណេះដឹងផ្នែកបច្ចេកវិទ្យា បន្ទុកការងាររៀបចំមេរៀនច្រើនសម្រាប់គ្រូបង្រៀន ទំនួលខុសត្រូវច្រើនសម្រាប់ការរៀនដោយស្វយ័តរបស់សិស្ស និងកង្វះខាតគាំទ្រសម្រាប់សិស្សជាដើម។ ដូច្នេះទាំងអ្នកអប់រំនិងគ្រូបង្រៀន ព្រមទាំងសិស្សានុសិស្សគួរទទួលបានការបណ្ដុះបណ្ដាលឱ្យបានគ្រប់គ្រាន់អំពីការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះជាមុនសិន មុននឹងអាចអនុវត្តវិធីសាស្ត្រដ៏មានសារៈប្រយោជន៍និងទំនើបមួយនេះប្រកបដោយប្រសិទ្ធភាព មិនមែនសម្រាប់តែការបង្រៀននិងរៀនអង់គ្លេសប៉ុណ្ណោះទេ ថែមទាំងអាចយកទៅអនុវត្តសម្រាប់មុខវិជ្ជាដ៏ទៃទៀតផងដែរឱ្យសមស្របទៅតាមការអប់រំសតវត្សរ៍ទី២១។

## ឯកសារយោង


Al Bataineh, K. B., Banikalef, A., & H Albashtawi, A. (2019). The effect of blended learning on EFL students' grammar performance and attitudes: An investigation of Moodle. *Arab World English Journal (AWEJ) Volume*, *10*.

Alam, S., Albozeidi, H. F., Al-Hawamdeh, B. O. S., & Ahmad, F. (2022). Practice and principle of blended learning in ESL/EFL pedagogy: strategies, techniques and challenges. *International Journal of Emerging Technologies in Learning (Online)*, *17*(11), 225.

Albiladi, W. S., & Alshareef, K. K. (2019). Blended learning in English teaching and learning: A review of the current literature. *Journal of Language Teaching and Research*, *10*(2), 232-238.

Ali, A., Khan, R. M. I., & Alouraini, A. (2023). A comparative study on the impact of online and blended learning. *SAGE Open*, *13*(1), 21582440231154417.

Bach, S., Haynes, P., & Smith, J. L. (2006). *Online learning and teaching in higher education.* Buckingham, UK: Open University Press.

Badawi, M. F. (2009). Using blended learning for enhancing EFL prospective teachers' pedagogical knowledge and performance. *Online Submission*.

Banados, E. (2006). A blended-learning pedagogical model for teaching and learning EFL successfully through an online interactive multimedia environment. *CALICO Journal, 23*(3), 533-550.

Banditvilai, C. (2016). Enhancing students' language skills through blended learning. *Electronic Journal of e-Learning, 14*(3), 220-229.

Benhadj, Y. (2021). A Quasi-experimental study on the impact of blended learning on EFL students′ language proficiency. *International Journal of Language and Literary Studies*, *3*(3), 146-155. http://doi.org/ 10.36892/ijlls.v3i3.668

Bijeikienė, V., Rašinskienė, S., & Zutkienė, L. (2011). Teachers′ attitudes towards the use of blended learning in general English classroom. *Studies about languages*, (18), 122-127.

Bonk, C. J., & Graham, C. R. (2012). The handbook of blended learning: Global perspectives, local designs. San Francisco, CA: John Wiley & Sons.

Compton, L. (2009). Preparing language teachers to teach language online: A look at skills, roles, and responsibilities. *Computer Assisted Language Learning, 22*(1),73-99.

Each, N., & Suppasetseree, S. (2021). The effects of mobile-blended cooperative learning on EFL students′ listening comprehension in Cambodian context. *LEARN Journal: Language Education and Acquisition Research Network*, *14*(2), 143-170.

Fedorova, A. (2020). Application of blended education models in teaching students of non-language universities a foreign language (English): Problems and prospects for implementing didactic goals. Retrieved from https://papers.ssrn.com/sol3/papers.cfm?abstract_id=3750648

Fırat Altay, İ., & Altay, A. (2019). A Review of Studies on Blended Learning in EFL Environment. *International Journal of Curriculum and Instruction*, *11*(1), 125-140.

Graham, C. R. (2006). Blended learning systems. In Bonk, C. J. & Graham, C. R. (Eds.). *Handbook of blended learning: Global Perspectives, local designs*. (3-21). San Francisco, CA: John Wiley & Sons

Graham, C. R., Allen, S., & Ure, D. (2005). Benefits and challenges of blended learning environments. In M. Khosrow-Pour (Ed.), *Encyclopedia of information science and technology* (pp. 253-259). Hershey, PA: Idea Group.

Graham, C. R., Allen, S., Ure, D., (2003). Blended learning environments. A review of the research literature. Unpublished manuscript, Brigham Young University.

Gulnaz, F., Althomali, A. D. A., & Alzeer, D. H. (2020). An investigation of the perceptions and experiences of the EFL teachers and learners about the effectiveness of blended learning at Taif University. *International Journal of English Linguistics*, *10*(1), 329-344.

Hampel, R. and Stickler, U. (2005) 'New skills for new classrooms: Training tutors to teach languages online', *Computer Assisted Language Learning*, 18 (4): 311-326.

Hong, K., & Samimy, K., (2010). The influence of L2 teachers' use of CALL modes on language learners' reactions to blended learning. *CALICO Journal,* 27(2), 328-348.

Kaplan, G. (2021). *The origins of blended learning*. Retrieved from https://jfynet.org/6535/authored-by-gary-kaplan/the-origins-of-blended-learning/

Kim, N. Y., & Yoon, S. Y. (2021). A comparative study on blended learning and flipped learning: EFL students' learner autonomy, independence, and attitudes. *Korean Journal of English Language and Linguistics*, *21*, 171-188. DOI: 10.15738/kjell.21..202103.171

Lim, D. H., Morris, M. L., & Kupritz, V. W. (2007). Online vs. blended learning: Differences in instructional outcomes and learner satisfaction. *Journal of Asynchronous Learning Networks*, *11*(2), 27-42.

MacDonald, J. (2008). *Blended learning and online tutoring: A good practice guide.* Aldershot, UK: Gower.

Marsh, D. (2012). Blended learning: Creating learning opportunities for language learners. New York, NY: Cambridge University Press.

Nissen, E., & Tea, E. (2012). Going blended: New challenges for second generation L2 tutors. Computer Assisted Language Learning, 25(2), 145-163. doi:10.1080/09588221.2011.636052

Neumeier, P. (2005). A closer look at blended learning: Parameters for designing a blended learning environment for language teaching and learning. *ReCALL, 17*, 163–178. doi: 10.1017/S0958344005000224

Owston, R., et al. (2006). Blended learning at Canadian universities: Issues and practices. In C. J. Bonk & C. R. Graham (Eds.), *The handbook of blended learning: Global perspectives, local designs* (pp. 338-350). San Francisco: Pfeiffer.

Ramalingam, S., Yunus, M. M., & Hashim, H. (2022). Blended learning strategies for sustainable English as a second language education: a systematic review. *Sustainability*, *14*(13), 8051.

Riel, J., Lawless, K. A., & Brown, S. W. (2016). Listening to the teachers: Using weekly online teacher logs for ROPD to identify teachers′ persistent challenges when implementing a blended learning curriculum. *Journal of Online Learning Research, 2*(2), 169-200.

Sharma, P. (2010). Blended learning. *ELT Journal, 64(4),* 456-458.

Thorne, K. (2003). *Blended learning: how to integrate online & traditional learning*. Kogan Page.

Topping, K. J., Douglas, W., Robertson, D., & Ferguson, N. (2022). Effectiveness of online and blended learning from schools: A systematic review. *Review of Education*, *10*(2), e3353.

Yang, Y. (2014). Preparing language teachers for blended teaching of summary writing. Computer Assisted Language Learning, 27(3), 185-206. doi:10.1080/09588221.2012.701633

Yoon, S. Y., & Lee, C. H. (2010). The perspectives and effectiveness of blended learning in L2 writing of Korean university students. *Multimedia Assisted Language Learning, 13*(2), 177-204.

Zhang, W., & Zhu, C. (2018). Comparing learning outcomes of blended learning and traditional face-to-face learning of university students in ESL courses. *International Journal on E-Learning, 17*(2), 251-273.